ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ២៦១៧ អពដ

ថ្ងៃ ពុធ ១រោច ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០២២

# សេចក្ដីណែនាំ
## ស្តីពី
## ការប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការសម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

អនុលោមតាមមាត្រា ៧៧ មាត្រា ៧៨ និងមាត្រា ៧៩ នៃច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិស្ដីពីអាករលើតម្លៃបន្ថែម កន្លងមក អគ្គនាយកដ្ឋានពន្ធដារ បានចេញសេចក្ដីណែនាំលេខ ១០៣៦២ អពដ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ ស្ដីពីការប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការសម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។ បន្ទាប់ពីបានប្រជុំពិភាក្សាជាមួយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ នូវរូបមន្តជ្រើសរើសយកអត្រាប្តូរប្រាក់មួយដែលឆ្លុះបញ្ចាំងពីទីផ្សារពិតប្រាកដ និងដោយបច្ចុប្បន្ននេះ ធនាគារជាតិនៃកម្ពុជា បានផ្លាស់ប្តូរវិធីសាស្ត្រថ្មីនៃការកំណត់អត្រាប្តូរប្រាក់ផ្លូវការ ដែលជាអត្រាអន្តរធនាគារអនុវត្តនៅក្នុងប្រព័ន្ធជួញដូររបស់ធនាគារជាតិនៃកម្ពុជា (National Bank of Cambodia Platform “NBCP”) និងបានឆ្លុះបញ្ចាំងពីអត្រាប្តូរប្រាក់ទីផ្សារជាក់ស្តែង។ ក្នុងគោលបំណងពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធប្រកបដោយប្រសិទ្ធភាព តម្លាភាព និងស័ក្តិសិទ្ធិភាព ជាពិសេសផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធក្នុងការប្រើប្រាស់អត្រាប្តូរប្រាក់ដែលសមស្របនឹងអត្រាប្តូរប្រាក់ទីផ្សារ អគ្គនាយកដ្ឋានពន្ធដារសម្រេចឱ្យអ្នកជាប់ពន្ធទាំងអស់ប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ដែលចេញផ្សាយប្រចាំថ្ងៃជំនួសវិញ។

ដូច្នេះ ដើម្បីធានាដល់ការអនុវត្តអត្រាប្តូរប្រាក់ផ្លូវការ សម្រាប់ការប្រកាសបង់ពន្ធឱ្យបានត្រឹមត្រូវ និងធានាដល់យន្តការផ្ទៀងផ្ទាត់វិក្កយបត្រឱ្យកាន់តែច្បាស់លាស់ ក៏ដូចជាជួយសម្រួលដល់ការអនុវត្តការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មអនឡាញឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ អគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការណែនាំដូចខាងក្រោម÷

### ១.អត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃ

អ្នកជាប់ពន្ធត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃដែលចេញដោយធនាគារជាតិនៃកម្ពុជា ឬអត្រាប្តូរប្រាក់ទីផ្សារ ប៉ុន្តែមិនត្រូវទាបជាងអត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា សម្រាប់រំលេចប្រាក់រៀលលើតម្លៃសរុបក្នុងវិក្កយបត្រ។ ក្នុងករណី ការផ្គត់ផ្គង់ត្រូវធ្វើឡើងនៅថ្ងៃឈប់សម្រាក ឬមុនម៉ោងដែលធនាគារជាតិនៃកម្ពុជាមិនទាន់បានចេញផ្សាយអត្រាប្តូរប្រាក់ផ្លូវការ អ្នកជាប់ពន្ធត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជាដែលបានចេញផ្សាយមុនមួយថ្ងៃ នៃថ្ងៃឈប់សម្រាក។

ចំពោះអ្នកជាប់ពន្ធអនិវាសនជនដែលបានចុះបញ្ជីអាករលើតម្លៃបន្ថែមសាមញ្ញ មិនតម្រូវឱ្យរំលេចប្រាក់រៀលលើតម្លៃសរុបក្នុងវិក្កយបត្រឡើយ។ ដោយឡែក សម្រាប់គោលដៅរៀបចំលិខិតប្រកាសពន្ធជាប្រាក់រៀល និងគណនាអាករលើតម្លៃបន្ថែមត្រូវបង់ អ្នកជាប់ពន្ធអនិវាសនជនត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការប្រចាំខែ ដូចមានចែងក្នុងចំណុចទី៣ នៃសេចក្ដីណែនាំនេះ។

## ២.អត្រាប្តូរប្រាក់ផ្លូវការសម្រាប់ពន្ធលើប្រាក់បៀវត្ស

អ្នកជាប់ពន្ធត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការដែលចេញដោយធនាគារជាតិនៃកម្ពុជា រៀងរាល់ថ្ងៃទី១៥ នៃខែនីមួយៗ សម្រាប់គណនាពន្ធលើប្រាក់បៀវត្ស។ ក្នុងករណី ថ្ងៃទី១៥ នៃខែនីមួយៗ ចំថ្ងៃឈប់សម្រាក ដែលធនាគារជាតិនៃកម្ពុជាមិនបានចេញផ្សាយអត្រាប្តូរប្រាក់ផ្លូវការ អ្នកជាប់ពន្ធត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ដែលបានចេញផ្សាយមុនមួយថ្ងៃ នៃថ្ងៃឈប់សម្រាក។

## ៣.អត្រាប្តូរប្រាក់ផ្លូវការប្រចាំខែ

អ្នកជាប់ពន្ធត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការដែលចេញដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃចុងក្រោយ នៃខែនីមួយៗ សម្រាប់គណនាពន្ធត្រូវបង់ប្រចាំខែ ចំពោះការផ្គត់ផ្គង់ដោយអ្នកជាប់ពន្ធអនិវាសនជនដែលបានចុះបញ្ជីអាករលើតម្លៃបន្ថែមសាមញ្ញ ឬប្រតិបត្តិការទាំងឡាយណាដែលមិនមានវិក្កយបត្រ ឬវិក្កយបត្រដូចជា ប្រតិបត្តិការដែលទទួលការផ្គត់ផ្គង់ពីបុគ្គលមិនស្ថិតក្នុងរបបស្វ័យប្រកាស ឬពីអនិវាសនជន ជាដើម។

## ៤.អត្រាប្តូរប្រាក់ផ្លូវការប្រចាំឆ្នាំ

អ្នកជាប់ពន្ធត្រូវប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការដែលចេញដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃចុងក្រោយ នៃខែធ្នូ នៃឆ្នាំនីមួយៗ សម្រាប់រៀបចំលិខិតប្រកាសពន្ធប្រចាំឆ្នាំ និងគណនាពន្ធត្រូវបង់ប្រចាំឆ្នាំ។

សេចក្តីណែនាំលេខ ១០៣៦២ អពដ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ ស្តីពីការប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការសម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវទុកជានិរាករណ៍។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមយ៉ាងមុតមាំថា គ្រប់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ គិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**គង់ វិបុល**